## វេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៤១

# របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

*ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០២១*

*ម៉ោង ៨:០០ ដល់ ១២:០០ ថ្ងៃត្រង់*

*តាមរយៈប្រព័ន្ធអនឡាញ **Google Meet***

## I. សេចក្តីផ្តើម

នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យមួយស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ ក្នុងនោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏ស្ថិតក្រោមច្បាប់ការងារនេះដែរ ហើយសមត្ថភាពរបស់អង្គការសមាគមនៅមានកម្រិតក្នុងការស្វែងយល់ពីអនុក្រឹត្យនេះ ដែលតម្រូវឲ្យមានការពន្យល់បន្ថែម។

ដើម្បីឆ្លើយតបនឹងតម្រូវការសមាជិករបស់ខ្លួនផង និងចូលរួមចំណែកទប់ស្កាត់នៃការរីករាលដាលនៃជម្ងឺកូវីដ ១៩ តាមរយៈការអនុវត្តវិធានការណ៍ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា **អង្គការ គ.ស.ក** នឹងរៀបចំវេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី៤១ តាមរយៈប្រព័ន្ធអនឡាញ(Google Meet) ក្រោមប្រធានបទ **របបប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។**

ត្រឹមខែធ្នូ ឆ្នាំ២០២០ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ហៅកាត់ថា (គសក) មានសមាជិកសរុបទាំងអស់ប្រហែលចំនួន ២០០ស្ថាប័ន ទាំងអង្គការក្នុងស្រុក និងអង្គការបរទេស ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុតសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

## II. គោលបំណងនៃវេទិការៀនសូត្រ

១. ចូលរួមផ្សព្វផ្សាយពីអនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

២. បង្កើនការយល់ដឹង និងអនុលោមភាពតាមអនុក្រឹត្យ

៣. បង្កើនទំនាក់ទំនងតាមប្រព័ន្ធអនឡាញ និងបណ្តាញទំនាក់ទំនងសង្គមក្នុងចំណោមអ្នកគ្រប់គ្រងធនធានមនុស្ស

DRAFT

## III. អ្នកចូលរួមគោលដៅ និងថ្លៃចូលវេទិការៀនសូត្រ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ **អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស** ដែលអញ្ជើញមកពី **សមាគម និងអង្គការមិនមែនរដ្ឋាភិបាល** ក្នុងប្រទេសកម្ពុជា។

- ផ្តល់ជូន ០២ កន្លែងដោយឥតគិតថ្លៃសម្រាប់**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាសមាជិករបស់អង្គការ គ.ស.ក**។ ប្រសិនបើអ្នកចូលរួមលើសពីការផ្តល់ជូន ត្រូវបង់ថ្លៃ ១០ដុល្លារក្នុងម្នាក់/វគ្គ(ចាប់ពីអ្នកទីបីទៅ)។
- ចំពោះ**សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**ដែលមិនមែនជាសមាជិក**អង្គការ គ.ស.ក** ត្រូវបង់ថ្លៃ ២០ ដុល្លារក្នុងម្នាក់/វគ្គ។

## IV. របៀបចុះឈ្មោះ

អ្នកចូលរួមទាំងអស់តម្រូវឲ្យចុះឈ្មោះជាមុន ដើម្បីទទួលបានតំណរថ្មី (New Link) ពីក្រុមការងារ អង្គការ គសក ក្នុងការចូលរួមវេទិការៀនសូត្រនេះ។ តំណរនឹងផ្ញើជូនអ្នកដែលបានចុះឈ្មោះ និងបំពេញតាមលក្ខខណ្ឌ**មួយថ្ងៃមុនវេទិកា**រៀនសូត្រចាប់ផ្តើម។

## V. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០-០៨:៣០ | ការចុះឈ្មោះអ្នកចូលរួម | • ក្រុមការងារ គសក |
| ០៨:៣០-០៨:៤០ | - ការណែនាំពីរបៀបប្រើ Google Meet និង បទបញ្ញាផ្ទៃក្នុងវគ្គ<br>- គោលបំណងវេទិការៀនសូត្រ | **លោក សុខ ណេង**<br>អ្នកឯកទេសផ្នែកឧបករណ៍មិនបង្ខំទំនាស់<br>អង្គការ គ.ស.ក |
| ០៨:៤០-០៨:៥០ | កិច្ចស្វាគមន៍ និងបើកកម្មវិធី | **អ្នកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិ អង្គការ គ.ស.ក |
| ០៨:៥០-១០:២០ | **បទបង្ហាញពី ៖**<br>- អនុក្រឹត្យស្តីពី របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ | **លោក សុក បូរ៉ា**<br>ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១០:២០-១១:៥០ | វេទិកាពិភាក្សា និងសំណួរចម្លើយ | |

| | | |
|---|---|---|
| ១១:៥០-១២:០០ | បិទកម្មវិធី | លោក ចាន់ កានិកា<br>ប្រធានធនធានមនុស្សអង្គការOxfam<br>និងជាមាជិកក្រុមការងារធនធានមនុស្ស |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។*

DRAFT